# សន្ធិសញ្ញាទីក្រុងប៊ុយដាប៉េស ស្តីពីការទទួលស្គាល់ជាអន្តរជាតិការតម្កល់មីក្រូសរីរាង្គសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម

ធ្វើនៅទីក្រុង ប៊ុយដាប៉េស ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧
ហើយបានធ្វើវិសោធនកម្ម ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៨០

## តារាងមាតិកា*


**បទប្បញ្ញត្តិផ្តើម**

មាត្រា១: ការបង្កើតសហភាព

មាត្រា២: និយមន័យ

**ជំពូកទី១: បទប្បញ្ញត្តិជាសារធាតុ**

មាត្រា៣: ការទទួលស្គាល់ និងអនុភាពនៃការតម្កល់មីក្រូសរីរាង្គ

មាត្រា៤: ការតម្កល់ជាថ្មី

មាត្រា៥: ការកម្រិតលើការនាំចេញនិងនាំចូល

មាត្រា៦: ឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

មាត្រា៧: ការទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

មាត្រា៨: ការបញ្ចប់ និង ការកម្រិតឋានៈអាជ្ញាធរតម្កល់អន្តរជាតិ

មាត្រា៩: អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល

**ជំពូកទី២ : បទប្បញ្ញត្តិរដ្ឋបាល**

មាត្រា១០: សន្និបាត

មាត្រា១១: ការិយាល័យអន្តរជាតិ

មាត្រា១២: បទបញ្ជា

**ជំពូកទី៣ : ការកែប្រែ និងវិសោធនកម្ម**

មាត្រា១៣: ការកែប្រែសន្ធិសញ្ញា


---

* តារាងមាតិកាត្រូវបានបន្ថែមសម្រាប់ផ្តល់ភាពងាយស្រួលដល់អ្នកអាន។ តារាងមាតិកានេះ មិនមានក្នុងអត្ថបទដើម(ជាភាសាអង់គ្លេស)នៃសន្ធិសញ្ញាឡើយ។

មាត្រា១៤:  វិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៅក្នុងសន្ធិសញ្ញា

**ជំពូកទី៤:   អវសានប្បញ្ញត្តិ**

មាត្រា១៥:  ការក្លាយជាភាគីសន្ធិសញ្ញា
មាត្រា១៦:  ការចូលជាធរមាននៃសន្ធិសញ្ញា
មាត្រា១៧:  ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា
មាត្រា១៨:  ការចុះហត្ថលេខា និងភាសានៃសន្ធិសញ្ញា
មាត្រា១៩:  ការតម្កល់សន្ធិសញ្ញា ការបញ្ជូនច្បាប់ចម្លង ការចុះបញ្ជីសន្ធិសញ្ញា
មាត្រា២០: ការជូនដំណឹង

# បទប្បញ្ញត្តិផ្តើម

## មាត្រា ១

## ការបង្កើតសហភាព

រដ្ឋទាំងឡាយជាភាគីសន្ធិសញ្ញានេះ (តទៅហៅថារដ្ឋហត្ថលេខី) បង្កើតសហភាពមួយ សម្រាប់ការទទួលស្គាល់ជាអន្តរជាតិ ការតម្កល់មីក្រូសរីរាង្គសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម។

## មាត្រា ២

## និយមន័យ

សម្រាប់គោលបំណង នៃសន្ធិសញ្ញានេះ និងបទបញ្ជា:

(i) ការយោងទៅ "ប្រកាសនីយបត្រតក្កកម្ម" ត្រូវបកស្រាយជាការយោងទៅប្រកាសនីយបត្រតក្កកម្មលើតក្កកម្ម វិញ្ញាបនបត្រតក្កករ វិញ្ញាបនបត្រមានអត្ថប្រយោជន៍ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រកាសនីយបត្រតក្កកម្ម ឬ វិញ្ញាបនបត្រនៃការបន្ថែម វិញ្ញាបនបត្រតក្កករលើការបន្ថែម និងវិញ្ញាបនបត្រមានអត្ថប្រយោជន៍លើការបន្ថែម

(ii) "ការតម្កល់មីក្រូសរីរាង្គ" អនុលោមតាមបរិបទដែលមានពាក្យទាំងនេះ សំដៅដល់សកម្មភាពនានាដូចខាងក្រោមដែលអានុភាពស្របតាមសន្ធិសញ្ញានេះនិងបទបញ្ជា: ការបញ្ជូនមីក្រូសរីរាង្គទៅអាជ្ញាធរតម្កល់អន្តរជាតិដែលទទួលនិងព្រមទទួលមីក្រូសរីរាង្គ ឬ ការរក្សាទុកមីក្រូសរីរាង្គដោយអាជ្ញាធរតម្កល់អន្តរជាតិឬទាំងការបញ្ជូននិងការរក្សាទុកទាំងនេះ

(iii) "នីតិវិធីប្រកាសនីយបត្រតក្កកម្ម" សំដៅដល់ នីតិវិធីរដ្ឋបាល ឬនីតិវិធីតុលាការ ដែលទាក់ទងនឹងសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬប្រកាសនីយបត្រតក្កកម្ម

(iv) "ការបោះពុម្ពផ្សាយសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម" សំដៅដល់ ការបោះពុម្ពផ្សាយជាផ្លូវការ ឬ ជាការដាក់បង្ហាញជាសាធារណៈជាផ្លូវការឱ្យសាធារណៈជនអង្កេត នៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬ ប្រកាសនីយបត្រតក្កកម្ម

(v) "អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល" សំដៅដល់អង្គការ ដែលបានធ្វើសេចក្តីប្រកាសតាមមាត្រា ៩(១)

(vi) "ការិយាល័យកម្មសិទ្ធិឧស្សាហកម្ម" សំដៅដល់ អាជ្ញាធរនៃរដ្ឋហត្ថលេខី ឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលមានសមត្ថកិច្ចផ្តល់ប្រកាសនីយបត្រតក្កកម្ម

(vii) "ស្ថាប័នតម្កល់" សំដៅដល់ ស្ថាប័នដែលទទួល យល់ព្រមទទួលនិងរក្សាទុកមីក្រូសរីរាង្គ និងផ្តល់គំរូមីក្រូសរីរាង្គទាំងនេះ

(viii) "អាជ្ញាធរតម្កល់អន្តរជាតិ" សំដៅដល់ ស្ថាប័នតម្កល់ដែលបានទទួលឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ដូចមានចែងក្នុងមាត្រា៧។

(ix) "អ្នកតម្កល់" សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបញ្ជូនមីក្រូសរីរាង្គទៅអាជ្ញាធរតម្កល់អន្តរជាតិ ដែលទទួល និងយល់ព្រមទទួលមីក្រូសរីរាង្គ និងអ្នកទទួលសិទ្ធិណាមួយពី រូបវន្តបុគ្គល ឬ នីតិបុគ្គលនេះ

(x) "សហភាព" សំដៅដល់ សហភាពដូចមានចែងក្នុងមាត្រា ១

(xi) "សន្និបាត" សំដៅដល់សន្និបាតដូចមានចែងក្នុងមាត្រា១០

(xii) "អង្គការ" សំដៅដល់ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

(xiii) "ការិយាល័យអន្តរជាតិ" សំដៅដល់ ការិយាល័យអន្តរជាតិនៃអង្គការ ហើយសំដៅដល់ ការិយាល័យសហភាពអន្តរជាតិសម្រាប់កិច្ចការពារកម្មសិទ្ធិបញ្ញា (BIRPI) ដរាបណានៅមាន

(xiv) "អគ្គនាយក" សំដៅដល់ អគ្គនាយកនៃអង្គការ

(xv) "បទបញ្ជា" សំដៅដល់បទបញ្ជាដូចមានចែងក្នុងមាត្រា ១២។

## ជំពូកទី១
## បទប្បញ្ញត្តិជាសារធាតុ
## មាត្រា៣
### ការទទួលស្គាល់ និង អនុភាពនៃការតម្កល់មីក្រូសរីរាង្គ

(១)

(ក) រដ្ឋហត្ថលេខីទាំងឡាយ ដែលអនុញ្ញាតឬទាមទារឱ្យតម្កល់មីក្រូសរីរាង្គសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម ត្រូវទទួលស្គាល់ការតម្កល់មីក្រូសរីរាង្គនៅអាជ្ញាធរតម្កល់អន្តរជាតិណាមួយ សម្រាប់គោលបំណងនេះ។ ការទទួលស្គាល់នេះត្រូវរួមបញ្ចូលការទទួលស្គាល់អង្គហេតុនិងកាលបរិច្ឆេទនៃការតម្កល់ ដូចបានបង្ហាញដោយ អាជ្ញាធរតម្កល់អន្តរជាតិ ហើយការទទួលស្គាល់អង្គហេតុ ដែលបានផ្តល់ជាគំរូគឺជាគំរូមីក្រូសរីរាង្គដែលបានតម្កល់។

(ខ) រដ្ឋហត្ថលេខីណាមួយ អាចទាមទារច្បាប់ចម្លងមួយនៃការទទួលយកការតម្កល់ដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ដែលចេញដោយអាជ្ញាធរតម្កល់អន្តរជាតិ។

(២) ពាក់ព័ន្ធនឹងបញ្ហាដែលបានបញ្ញត្តិក្នុងសន្ធិសញ្ញានេះនិងបទបញ្ជា រដ្ឋហត្ថលេខី មិនអាចតម្រូវឱ្យគោរពតាមលក្ខខណ្ឌផ្សេង ឬលក្ខខណ្ឌបន្ថែមលើលក្ខខណ្ឌទាំងឡាយ ដែល

មានចែងក្នុងសន្ធិសញ្ញានេះនិងបទបញ្ជា។

## មាត្រា៤

## ការតម្កល់ជាថ្មី

(១)

(ក) នៅពេលដែលអាជ្ញាធរតម្កល់អន្តរជាតិ មិនអាចផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ ដោយមូលហេតុណាមួយ ជាពិសេស

(i) នៅពេលដែលមីក្រូសរីរាង្គលែងមានជីវិតតទៅទៀត ឬ

(ii) នៅពេលផ្តល់គំរូ បើតម្រូវឱ្យផ្ញើគំរូទាំងនេះទៅបរទេសហើយការផ្ញើឬការទទួលគំរូនៅបរទេស ត្រូវបានរារាំងដោយការកម្រិតលើការនាំចេញ ឬ ការនាំចូល បន្ទាប់ពីដឹងថាគ្មានលទ្ធភាពផ្តល់គំរូភ្លាម អាជ្ញាធរនេះត្រូវជូនដំណឹងដល់អ្នកតម្កល់ ដោយបង្ហាញពីមូលហេតុ។ យោងតាមកថាខណ្ឌទី(២)និងដូចមានចែងក្នុងកថាខណ្ឌនេះ អ្នកតម្កល់ត្រូវមានសិទ្ធិតម្កល់ជាថ្មីនូវមីក្រូសរីរាង្គដែលបានតម្កល់ពីមុន។

(ខ) ការតម្កល់ជាថ្មី ត្រូវធ្វើឡើងនៅអាជ្ញាធរតម្កល់អន្តរជាតិដែលបានធ្វើការតម្កល់ពីមុន ឱ្យតែ:

(i) ការតម្កល់នេះ ត្រូវធ្វើនៅអាជ្ញាធរតម្កល់អន្តរជាតិមួយផ្សេងទៀត នៅពេលដែលស្ថាប័នដែលបានធ្វើការតម្កល់ពីមុន លែងមានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ទោះទាំងស្រុងឬតាមប្រភេទមីក្រូសរីរាង្គដែលបានតម្កល់ ឬនៅពេលដែលអាជ្ញាធរតម្កល់អន្តរជាតិដែលបានតម្កល់ពីមុន លែងបំពេញមុខងារតម្កល់មីក្រូសរីរាង្គរបស់ខ្លួនជាបណ្តោះអាសន្ន ឬជាស្ថាពរ

(ii) ការតម្កល់នេះអាចធ្វើនៅអាជ្ញាធរតម្កល់អន្តរជាតិមួយផ្សេងទៀតបានក្នុងករណីដូចមានចែងក្នុងអនុកថាខណ្ឌ(ក)(ii)។

(គ) ការរតម្កល់ជាថ្មីណាមួយ ត្រូវមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែលបានចុះហត្ថលេខាដោយអ្នកតម្កល់ដែលអះអាងថាមីក្រូសរីរាង្គដែលតម្កល់ជាថ្មីនេះ គឺដូចនឹងមីក្រូសរីរាង្គដែកបានតម្កល់ពីមុន។ ប្រសិនបើ ការអះអាងរបស់អ្នកតម្កល់ ត្រូវបានជំទាស់ បន្ទុកភស្តុតាងត្រូវគ្រប់គ្រងដោយច្បាប់ដែលអនុវត្ត។

(ឃ) យោងតាមអនុកថាខណ្ឌ(ក) ដល់ (គ) និង (ង) ការតម្កល់ជាថ្មី ត្រូវបានចាត់ទុកថាបានធ្វើតាមកាលបរិច្ឆេទនៃការតម្កល់ពីមុន នៅពេលដែលសេចក្តីថ្លែងទាំងឡាយពីមុនពាក់ព័ន្ធនឹងភាពមានជីវិតនៃមីក្រូសរីរាង្គដែលបានតម្កល់ពីមុន បានបង្ហាញថា មីក្រូសរីរាង្គនេះ នៅមានជីវិត ហើយនៅពេលការតម្កល់ជាថ្មីនេះ ត្រូវបានធ្វើក្នុងអំឡុងពេល

៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអ្នកតម្កល់ទទួលបានសេចក្តីជូនដំណឹងដូចមានចែងក្នុងអនុកថាខណ្ឌ(ក)។

(ង) ពេលអនុវត្តអនុកថាខណ្ឌ(ខ)(i) ហើយពេលដែលអ្នកតម្កល់មិនបានទទួលសេចក្តីជូនដំណឹង ដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិបានបោះពុម្ពផ្សាយ ការបញ្ចប់ ការកម្រិត ឬការឈប់ដូចមានចែងក្នុងអនុកថាខណ្ឌ(ខ)(i) រយៈពេលកំណត់៣(បី)ខែ ដូចមានចែងក្នុងអនុកថាខណ្ឌ(ឃ) ត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយនេះ។

(២) សិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី(១)(ក)លែងមានទៀត នៅពេលដែលមីក្រូសរីរាង្គដែលបានតម្កល់ត្រូវបានផ្ទេរទៅអាជ្ញាធរតម្កល់អន្តរជាតិមួយផ្សេងទៀត ឱ្យតែអាជ្ញាធរនេះមានលទ្ធភាពផ្តល់គំរូមីក្រូសរីរាង្គ។

## មាត្រា៥

## ការកម្រិតការនាំចេញនិងការនាំចូល

ប្រសិនបើនិងក្នុងករណីដែលមានការកម្រិតការនាំចេញពីដែនដីរបស់ខ្លួន ឬការនាំចូលក្នុងដែនដីរបស់ខ្លួននូវមីក្រូសរីរាង្គប្រភេទខ្លះ រដ្ឋហត្ថលេខីនីមួយៗ ទទួលស្គាល់ថាការកម្រិតនេះ គួរត្រូវបានអនុវត្តចំពោះមីក្រូសរីរាង្គដែលបានតម្កល់ឬនឹងតម្កល់តាមអត្ថន័យនៃសន្ធិសញ្ញានេះ តែកាលបើការកម្រិតនេះមានភាពចាំបាច់ដោយមូលហេតុសន្តិសុខជាតិឬគ្រោះថ្នាក់ដល់សុខភាពឬបរិស្ថាន។

## មាត្រា៦

## ឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

(១) ដើម្បីឱ្យមានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ស្ថាប័នតម្កល់ណាមួយ ត្រូវមានទីតាំងលើដែនដីនៃរដ្ឋហត្ថលេខីណាមួយ ហើយត្រូវទទួលការធានាពីរដ្ឋនេះថា ស្ថាប័ននេះគោរពតាម ហើយនឹងបន្តគោរពតាមលក្ខខណ្ឌនានាដែលកំណត់ក្នុងកថាខណ្ឌទី(២)។ ការធានានេះ ក៏អាចត្រូវបានផ្តល់ឱ្យផងដែរដោយអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ក្នុងករណីនេះ ស្ថាប័នតម្កល់ ត្រូវមានទីតាំងលើដែនដី រដ្ឋជាសមាជិកណាមួយនៃអង្គការនេះ។

(២) ក្នុងសមត្ថកិច្ចជាអាជ្ញាធរតម្កល់អន្តរជាតិរបស់ខ្លួន ស្ថាប័នតម្កល់ត្រូវៈ

(i) មានអត្ថិភាពជានិរន្តន៍

(ii) មានបុគ្គលិកនិងសម្ភារៈចាំបាច់នានាដើម្បីបំពេញការងារវិទ្យាសាស្ត្រ និងការងាររដ្ឋបាលរបស់ខ្លួនតាមសន្ធិសញ្ញានេះ ដូចមានចែងក្នុងបទបញ្ជា

(iii) មិនលំអៀង និងមានលក្ខណៈសត្យានុម័ត

(iv) ក្នុងគោលបំណងតម្កល់ ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់អ្នកតម្កល់ ក្នុងលក្ខខណ្ឌដូចៗគ្នា

(v) ទទួលយកការតម្កល់ប្រភេទមីក្រូសរីរាង្គណាមួយ ឬប្រភេទមីក្រូសរីរាង្គមួយចំនួន ត្រួតពិនិត្យភាពមានជីវិត និងរក្សាទុកមីក្រូសរីរាង្គទាំងនេះ ដូចមានចែងក្នុងបទបញ្ជា

(vi) ចេញបង្កាន់ដៃឱ្យអ្នកតម្កល់ និងចេញសេចក្តីអះអាងស្តីពីភាពមានជីវិត ដូចមានចែងក្នុងបទបញ្ជា

(vii) ចំពោះមីក្រូសរីរាង្គដែលបានតម្កល់ គោរពតាមលក្ខខណ្ឌការសម្ងាត់ ដូចមានចែងក្នុងបទបញ្ជា

(viii) ផ្តល់គំរូមីក្រូសរីរាង្គនានាដែលបានតម្កល់តាមលក្ខខណ្ឌ និងស្របតាមនីតិវិធីដែលបានកំណត់ក្នុងបទបញ្ជា។

(៣) បទបញ្ជាត្រូវចែងអំពីការចាត់វិធានការនានា:

(i) នៅពេលដែលអាជ្ញាធរតម្កល់អន្តរជាតិមួយ ឈប់បំពេញមុខងាររបស់ខ្លួនជាបណ្តោះអាសន្នឬជា ស្ថាពរទាក់ទងនឹងមីក្រូសរីរាង្គដែលបានតម្កល់ ឬ បដិសេធមិនទទួលយកប្រភេទមីក្រូសរីរាង្គណាមួយដែលខ្លួនគួរទទួល តាមការធានារបស់ខ្លួន

(ii) ក្នុងករណី បញ្ចប់ ឬ កម្រិត ឋានៈអាជ្ញាធរតម្កល់អន្តរជាតិរបស់អាជ្ញាធរតម្កល់អន្តរជាតិ។

## មាត្រា៧
## ការទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

(១)

(ក) ស្ថាប័នតម្កល់មួយត្រូវទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកដោយរដ្ឋហត្ថលេខី លើដែនដី ដែលស្ថាប័នតម្កល់តាំងនៅ និងរួមទាំងសេចក្តីប្រកាសពីការធានាថាស្ថាប័ននេះគោរពតាម ហើយនឹងបន្តគោរពតាមលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា៦(២)។ ឋានៈនេះ អាចទទួលបានផងដែរ តាមរយៈ សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក ដោយអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល និងរួមទាំងសេចក្តីប្រកាសដូចបានលើកឡើងខាងលើ។

(ខ) សេចក្តីជូនដំណឹង ត្រូវមានផងដែរនូវព័ត៌មានអំពីស្ថាប័នតម្កល់ ដូចមានចែងក្នុងបទបញ្ជា និងអាចបញ្ជាក់ពីកាលបរិច្ឆេទនៃអានុភាពអនុវត្តចំពោះឋានៈជាអាជ្ញាធរ

តម្កល់អន្តរជាតិ។

(២)

(ក) ប្រសិនបើអគ្គនាយកយល់ឃើញថា សេចក្តីជូនដំណឹង មានបញ្ចូលសេចក្តីប្រកាសដែលទាមទារ ហើយព័ត៌មានទាំងអស់ដែលទាមទារត្រូវបានទទួលរួចហើយ ការិយាល័យអន្តរជាតិ ត្រូវបោះពុម្ពផ្សាយសេចក្តីជូនដំណឹងនេះភ្លាម។

(ខ) ឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ត្រូវទទួលបានចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយសេចក្តីជូនដំណឹង ឬ នៅពេលដែលមានការបង្ហាញកាលបរិច្ឆេទតាមកថាខណ្ឌទី(១)(ខ) ហើយកាលបរិច្ឆេទនេះធ្វើឡើងក្រោយកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយសេចក្តីជូនដំណឹង ឋានៈនេះត្រូវទទួលបានចាប់ពីកាលបរិច្ឆេទក្រោយនេះ។

(៣) សេចក្តីលម្អិតនៃនីតិវិធីតាមកថាខណ្ឌទី(១) និងទី(២)ត្រូវចែងក្នុងបទបញ្ជា។

## មាត្រា៨

## ការបញ្ចប់ និង ការកម្រិតឋានៈអាជ្ញាធរតម្កល់អន្តរជាតិ

(១)

(ក) រដ្ឋហត្ថលេខី ឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលណាមួយ អាចស្នើសន្និបាតឱ្យបញ្ចប់ឬឱ្យកម្រិតប្រភេទមីក្រូសរីរាង្គមួយចំនួន ឋានៈអាជ្ញាធរនៃអាជ្ញាធរតម្កល់អន្តរជាតិណាមួយ ដោយមូលហេតុថាលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦ មិនបានបំពេញឬលែងបានបំពេញតទៅទៀត។ ប៉ុន្តែ សំណើនេះមិនអាចត្រូវបានលើកឡើងដោយរដ្ឋហត្ថលេខីឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ទាក់ទងនឹងអាជ្ញាធរតម្កល់អន្តរជាតិដែលរដ្ឋហត្ថលេខីឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលនេះបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងមាត្រា៧(១)(ក)។

(ខ) មុនពេលធ្វើសំណើតាមអនុកថាខណ្ឌ(ក) តាមរយៈអន្តរការីនៃអគ្គនាយក រដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ត្រូវជូនដំណឹងពីហេតុផលនៃការលើកសំណើនេះទៅរដ្ឋហត្ថលេខីឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលបានជូនដំណឹង ដូចមានចែងក្នុងមាត្រា៧(១) ដើម្បីឱ្យរដ្ឋឬអង្គការនេះអាចចាត់វិធានការសមស្របដើម្បីដកចេញការលើកសំណើនេះ ក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ។

(គ) នៅពេលដែលសន្និបាតយល់ឃើញថា សំណើនេះមានមូលដ្ឋានត្រឹមត្រូវ សន្និបាតត្រូវសំរេចបញ្ចប់ ឬកម្រិតចប្រភេទមីក្រូសរីរាង្គមួយចំនួន ឋានៈអាជ្ញាធរតម្កល់អន្តរជាតិនៃអាជ្ញាធរដូចមានចែងក្នុងអនុកថាខណ្ឌ(ក)។ សេចក្តីសំរេចរបស់សន្និបាតត្រូវ

ទាមទារសំលេងភាគច្រើន២/៣(ពីរភាគបី)នៃសំលេងឆ្នោតដែលបានបោះគាំទ្រសំណើ។

(២)

(ក) រដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលដែលបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងមាត្រា៧(១)(ក) តាមរយៈការជូនដំណឹងទៅអគ្គនាយក អាចដកសេចក្តីប្រកាសរបស់ខ្លួនទាំងស្រុងឬចំពោះតែប្រភេទមីក្រូសរីរាង្គមួយចំនួន ហើយទោះជាយ៉ាងណាក៏ដោយ ត្រូវធ្វើបែបនេះ នៅពេលនិងត្រឹមកម្រិតដែលការធានារបស់ខ្លួនលែងអនុវត្តបានតទៅទៀត។

(ខ) ចាប់ពីកាលបរិច្ឆេទដូចមានចែងក្នុងបទបញ្ជា នៅពេលដែលសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងសេចក្តីប្រកាសទាំងមូល សេចក្តីជូនដំណឹងនេះត្រូវបញ្ចប់ឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ឬនៅពេលដែលសេចក្តីជូនដំណឹងនេះពាក់ព័ន្ធតែប្រភេទមីក្រូសរីរាង្គមួយចំនួន សេចក្តីជូនដំណឹងនេះបណ្តាលឱ្យមានការកម្រិតមួយចំនួនចំពោះឋានៈនេះ។

(៣) សេចក្តីលម្អិតនៃនីតិវិធីតាមកថាខណ្ឌទី(១) និងទី(២) ត្រូវចែងក្នុងបទបញ្ជា។

## មាត្រា៩

## អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល

(១)

(ក) អង្គការអន្តររដ្ឋាភិបាលណាមួយ ដែលរដ្ឋមួយចំនួនបានប្រគល់ការងារផ្តល់ប្រកាសនីយបត្រតក្កកម្មតំបន់ ហើយដែលរដ្ឋជាសមាជិកទាំងអស់របស់ខ្លួនជាសមាជិកសហភាពអន្តរជាតិ (ប៉ារីស) ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម អាចដាក់សេចក្តីប្រកាសទៅអគ្គនាយកថាខ្លួនយល់ព្រមទទួលយក កាតព្វកិច្ចនៃការទទួលស្គាល់ដូចមានចែងក្នុងមាត្រា៣ (១)(ក) កាតព្វកិច្ចពាក់ព័ន្ធនឹងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣(២) និងអនុភាពទាំងអស់នៃបទប្បញ្ញត្តិរបស់សន្ធិសញ្ញានេះនិងបទបញ្ជា ដែលអនុវត្តចំពោះអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល។ ប្រសិនបើបានដាក់មុនការចូលធរមាននៃសន្ធិសញ្ញានេះអនុលោមតាមមាត្រា១៦(១) សេចក្តីប្រកាសដូចយោងទៅឃ្លាខាងលើត្រូវមានអានុភាពអនុវត្តតាមកាលបរិច្ឆេទនៃការចូលជាធរមាននេះ។ ប្រសិនបើដាក់ក្រោយការចូលធរមាននេះ សេចក្តីប្រកាសនេះ ត្រូវមានអានុភាពអនុវត្ត៣(បី)ខែបន្ទាប់ពីការដាក់សេចក្តីប្រកាសនេះ លើកលែងតែមានការបង្ហាញកាលបរិច្ឆេទក្រោយក្នុងសេចក្តីប្រកាស។ ក្នុងករណីក្រោយនេះ សេចក្តីប្រកាសនេះ ត្រូវមានអានុភាពអនុវត្តតាមកាលបរិច្ឆេទដែលបានបង្ហាញនេះ។

(ខ) អង្គការនេះ ត្រូវមានសិទ្ធិ ដូចមានចែងក្នុងមាត្រា៣(១)(ខ)។

(២) នៅពេលដែលបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញានេះឬនៃបទបញ្ជា ដែលប៉ះពាល់ដល់អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ត្រូវបានកែប្រែឬធ្វើវិសោធនកម្ម អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលណាមួយ អាចដកសេចក្តីប្រកាសរបស់ខ្លួន ដូចមាន

ចែងក្នុងកថាខណ្ឌទី(១) ដោយជូនដំណឹងទៅអគ្គនាយក។ ការដកនេះត្រូវមានអានុភាពៈ

(i) តាមកាលបរិច្ឆេទនេះ នៅពេលដែលបានទទួលសេចក្តីជូនដំណឹង មុនកាលបរិច្ឆេទចូលជាធរមាននៃ ការកែប្រែ ឬការធ្វើវិសោធនកម្ម

(ii) តាមកាលបរិច្ឆេទដែលបង្ហាញក្នុងសេចក្តីជូនដំណឹង នៅពេលដែលបានទទួលសេចក្តីជូនដំណឹងនេះបន្ទាប់ពីកាលបរិច្ឆេទដូចមានចែងក្នុង(i) ឬ៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹង ក្នុងករណីគ្មានការបង្ហាញនេះ ។

(៣) បន្ថែមលើករណីដូចមានចែងក្នុងកថាខណ្ឌទី(២) អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលណាមួយ អាចដកសេចក្តីប្រកាសរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌទី(១)(ក) ដោយជូនដំណឹងទៅអគ្គនាយក។ ការដកនេះ ត្រូវមានអានុភាព ២(ពីរ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកទទួលបានការជូនដំណឹង។ សេចក្តីជូនដំណឹង ពីការដកចេញ តាមកថាខណ្ឌនេះ មិនអាចទទួលបានឡើយក្នុងអំឡុងពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលសេចក្តីប្រកាសនេះមានអានុភាពអនុវត្ត។

(៤) ការដកដូចមានចែងក្នុងកថាខណ្ឌទី(២)ឬទី(៣) ដោយអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលសេចក្តីជូនដំណឹងរបស់ខ្លួនតាមមាត្រា៧(១) ធ្វើឱ្យស្ថាប័នតម្កល់មួយទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ធ្វើឱ្យបញ្ចប់ឋានៈនេះ ក្នុងរយៈពេល១(មួយ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកទទួលបានការជូនដំណឹងពីការដកនេះ។

(៥) សេចក្តីប្រកាសណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី(១)(ក) ការជូនដំណឹងពីការដកដូចមានចែងក្នុងកថាខណ្ឌទី(២)ឬទី(៣) ការធានាដែលបានផ្តល់តាមមាត្រា៦(១) ឃ្លាទី២ និងតាមសេចក្តីប្រកាសដែលធ្វើឡើងស្របតាមមាត្រា៧(១)(ក) សំណើដែលធ្វើឡើងតាមមាត្រា៨(១)និងការជូនដំណឹងពីការដកចេញដូចមានចែងក្នុងមាត្រា៨(២) ត្រូវទាមទារឱ្យមានការយល់ព្រមជាក់លាក់ជាមុន ពីអង្គភាពគ្រប់គ្រងកំពូលនៃអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលមានសមាជិក ជារដ្ឋទាំងអស់ដែលជាសមាជិកអង្គការនេះ ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងដោយតំណាងផ្លូវការរបស់រដ្ឋាភិបាលនៃ រដ្ឋទាំងនេះ។

## ជំពូកទី២
## បទប្បញ្ញត្តិរដ្ឋបាល

### មាត្រា១០
### សន្និបាត

(១)

(ក) សន្និបាតត្រូវមានរដ្ឋលេខីទាំងឡាយចូលរួម។

(ខ) រដ្ឋហត្ថលេខីនីមួយៗត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាចអមដោយ ប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

(គ) អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលនីមួយៗ ត្រូវតំណាងដោយអ្នកសង្កេតការណ៍ពិសេសក្នុងកិច្ចប្រជុំទាំងឡាយរបស់សន្និបាត និងក្នុងគណៈកម្មាធិការ និងក្រុមការងារណាមួយដែលបង្កើតឡើងដោយសន្និបាត។

(ឃ) រដ្ឋណាមួយមិនមែនជាសមាជិកសហភាព ដែលជា សមាជិកអង្គការ ឬជាសមាជិកសហភាពអន្តរជាតិ(ប៉ារីស) ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងអង្គការអន្តររដ្ឋាភិបាលណាមួយដែលជំនាញក្នុងវិស័យប្រកាសនីយបត្រតក្កកម្ម ក្រៅពីអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលដូចបានកំណត់ក្នុងមាត្រា២(v) អាចតំណាងដោយអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំទាំងឡាយរបស់សន្និបាត និងក្នុងកិច្ចប្រជុំទាំងឡាយរបស់គណៈកម្មាធិការឬក្រុមការងារណាមួយ ដែលបង្កើតដោយសន្និបាត ប្រសិនបើ សន្និបាតសម្រេចដូច្នេះ។

(២)

(ក) សន្និបាតត្រូវៈ

- (i) ដោះស្រាយរាល់បញ្ហា ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍ សហភាព ព្រមទាំង ការអនុវត្តន៍សន្ធិសញ្ញានេះ
- (ii) អនុវត្តសិទ្ធិនេះនិងបំពេញការងារដែលបានប្រគល់ឱ្យ ឬចាត់តាំងជាពិសេស តាមសន្ធិសញ្ញានេះ
- (iii) ណែនាំអគ្គនាយកអំពីការរៀបចំសន្និសីទកែប្រែ
- (iv) ពិនិត្យនិងអនុម័តរបាយការណ៍និងសកម្មភាពរបស់អគ្គនាយកទាក់ទងនឹងសហភាព និងផ្តល់ការណែនាំចាំបាច់នានា ដល់អគ្គនាយកទាក់ទងនឹងបញ្ហាក្នុងសមត្ថកិច្ចរបស់សហភាព
- (v) បង្កើតគណៈកម្មាធិការ និងក្រុមការងារដែលយល់ថាសមស្របដើម្បី ជួយ សម្រួលការងារសហភាព
- (vi) យោងតាមកថាខណ្ឌទី(១)(ឃ) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំ ក្នុងឋានៈជាអ្នកសង្កេតការណ៍ ចំពោះរដ្ឋក្រៅពីរដ្ឋហត្ថលេខី ចំពោះអង្គការអន្តររដ្ឋាភិបាល ក្រៅពីអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលដូចមានចែងក្នុងមាត្រា២(v) និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងកំណត់វិសាលភាពក្នុងការចូលរួមកិច្ចប្រជុំជាអ្នកសង្កេតការណ៍ដោយអាជ្ញាធរតម្កល់អន្តរជាតិ

(vii) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាព

(viii) បំពេញមុខងារផ្សេងទៀតដែលស្របតាមអនុសញ្ញានេះ

(ខ) ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៣) ប្រតិភូម្នាក់អាចតំណាង និងបោះឆ្នោតក្នុងនាមរដ្ឋមួយតែប៉ុណ្ណោះ។

(៤) រដ្ឋហត្ថលេខីនីមួយៗ ត្រូវមានសំលេងឆ្នោតតែមួយ។

(៥)

(ក) កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃរដ្ឋហត្ថលេខី។

(ខ) ក្នុងករណីមិនគ្រប់កូរ៉ុម សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះត្រូវយកមកអនុវត្តបានតែក្នុងករណីកូរ៉ុមនិងការទាមទារសំលេងភាគច្រើនទទួលបានតាមការបោះឆ្នោតពីចម្ងាយដូចមានចែងក្នុងបទបញ្ជា លើកលែងតែសេចក្តីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាត។

(៦)

(ក) យោងតាមមាត្រា៨(១)(គ) មាត្រា១២(៤)និងមាត្រា១៤(២)(ខ)សេចក្តីសម្រេចរបស់សន្និបាតទាមទារសំលេងភាគីច្រើននៃសំលេងឆ្នោតដែលបានបោះ។

(ខ) អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

(៧)

(ក) សន្និបាតត្រូវប្រជុំសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើអាចធ្វើទៅបាន តាមពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ។

(ខ) តាមសំណើសុំពីអគ្គនាយក ឬពីរដ្ឋហត្ថលេខីចំនួន១/៤(មួយភាគបួន) សន្និបាតត្រូវប្រជុំជាវិសាមញ្ញ តាមការកោះប្រជុំរបស់អគ្គនាយក ។

(៨) សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា១១

## ការិយាល័យអន្តរជាតិ

(១) ការិយាល័យអន្តរជាតិត្រូវៈ

(i) បំពេញការងាររដ្ឋបាលដែលពាក់ព័ន្ធនឹងសហភាព ជាពិសេស ការងារដែលប្រគល់ឱ្យជាពិសេសដោយសន្ធិសញ្ញានេះ និងបទបញ្ជា ឬដោយសន្និបាត

(ii) បំរើការងារជាលេខាធិការដ្ឋានសម្រាប់សន្និសីទកែប្រែ សន្និបាត គណៈកម្មាធិការនិងក្រុមការងារដែលបង្កើតដោយសន្និបាត និង សម្រាប់កិច្ចប្រជុំផ្សេងទៀតដែលកោះប្រជុំដោយអគ្គនាយក និងពិភាក្សាបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសហភាព។

(២) អគ្គនាយកត្រូវជានាយកប្រតិបត្តិនៃសហភាពនិងជាតំណាងសហភាព។

(៣) អគ្គនាយកត្រូវកោះប្រជុំកិច្ចប្រជុំទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានៃសហភាព។

(៤)

(ក) អគ្គនាយក និងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកត្រូវចូលរួមរាល់កិច្ចប្រជុំសន្និបាត គណៈកម្មាធិការនិងក្រុមការងារដែលបង្កើតឡើងដោយសន្និបាត និងកិច្ចប្រជុំផ្សេងទៀតដែលកោះប្រជុំដោយអគ្គនាយក និងពិភាក្សាបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសហភាព តែគ្មានសិទ្ធិបោះឆ្នោតទេ។

(ខ) អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកគឺជាលេខាដោយស្វ័យប្រវត្តិរបស់សន្និបាត គណៈកម្មាធិការ ក្រុមការងារ និងកិច្ចប្រជុំផ្សេងទៀតដូចមានចែងក្នុងអនុកថាខណ្ឌ(ក)។

(៥)

(ក) តាមសេចក្តីណែនាំរបស់សន្និបាត អគ្គនាយកត្រូវរៀបចំសន្និសីទកែប្រែ។

(ខ) អគ្គនាយកអាចពិគ្រោះយោបល់ជាមួយអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ។

(គ) អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទកែប្រែ តែគ្មានសិទ្ធិបោះឆ្នោតទេ។

(ឃ) អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកគឺជាលេខាដោយស្វ័យប្រវត្តិរបស់សន្និសីទកែប្រែណាមួយ។

## មាត្រា១២

## បទបញ្ជា

(១) បទបញ្ជាចែងពីប្រការទាំងឡាយពាក់ព័ន្ធនឹង:

(i) បញ្ហាទាំងឡាយដែលសន្និសញ្ញានេះយោងយ៉ាងច្បាស់ទៅបទបញ្ជា ឬ សន្និសញ្ញានេះចែងយ៉ាងច្បាស់ថា កំណត់ឬត្រូវកំណត់ក្នុងបទបញ្ជា

(ii) លក្ខខណ្ឌរដ្ឋបាល បញ្ហា ឬនីតិវិធីនានា

(iii) សេចក្តីលម្អិតដែលមានប្រយោជន៍ណាមួយក្នុងការអនុវត្តន៍សន្និសញ្ញានេះ។

(២) បទបញ្ជាទាំងឡាយដែលអនុម័តនៅពេលតែមួយជាមួយសន្ធិសញ្ញានេះត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះ។

(៣) សន្និបាតអាចធ្វើវិសោធនកម្មបទបញ្ជាបាន។

(៤)

(ក) យោងតាមអនុកថាខណ្ឌ(ខ) ការអនុម័តវិសោធនកម្មណាមួយនៃបទបញ្ជា ទាមទារសំលេង ២/៣(ពីរភាគបី)នៃសំលេងឆ្នោតដែលបានបោះ។

(ខ) ការអនុម័តវិសោធនកម្មណាមួយពាក់ព័ន្ធនឹងការផ្តល់គំរូមីក្រូសរីរាង្គ ដែលបានតម្កល់ ដោយអាជ្ញាធរតម្កល់អន្តរជាតិតម្រូវថាគ្មានរដ្ឋហត្ថលេខីណាបោះឆ្នោតជំទាស់នឹងសំណើធ្វើវិសោធនកម្មនេះ។

(៥) ក្នុងករណីមានវិវាទរវាងបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ និងប្រការនៃបទបញ្ជា បទប្បញ្ញត្តិនៃសន្ធិសញ្ញាត្រូវយកជាគោល។

## ជំពូកទី៣
## ការកែប្រែ និងវិសោធនកម្ម

### មាត្រា១៣
### ការកែប្រែសន្ធិសញ្ញា

(១) សន្ធិសញ្ញានេះអាចកែប្រែពេលណាក៏បាន ដោយសន្និសីទនៃរដ្ឋហត្ថលេខី។

(២) ការកោះប្រជុំសន្និសីទកែប្រែណាមួយត្រូវសម្រេចដោយសន្និបាត។

(៣) មាត្រា១០ និងមាត្រា១១ អាចធ្វើវិសោធនកម្មដោយសន្និសីទកែប្រែ ឬដោយអនុលោមតាមមាត្រា១៤។

### មាត្រា១៤
### វិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃសន្ធិសញ្ញា

(១)

(ក) ការស្នើសុំតាមមាត្រានេះចំពោះវិសោធនកម្មមាត្រា១០ និងមាត្រា១១ អាចផ្តួចផ្តើម ដោយរដ្ឋហត្ថលេខីណាមួយ ឬដោយអគ្គនាយក។

(ខ) អគ្គនាយកត្រូវផ្តល់ព័ត៌មានពីសំណើនេះ ទៅរដ្ឋហត្ថលេខីទាំងឡាយ យ៉ាងហោចណាស់ ៦(ប្រាំមួយ)ខែ មុនសន្និបាតលើកយកមកពិចារណា។

(២)

(ក)វិសោធនកម្មមាត្រាទាំងឡាយដូចមានចែងក្នុងកថាខណ្ឌទី(១) ត្រូវអនុម័តដោយសន្និបាត។

(ខ) ការអនុម័តវិសោធនកម្មណាមួយចំពោះមាត្រា១០ ទាមទារសំលេង ៤/៥(បួនភាគប្រាំ)នៃសំលេងឆ្នោតដែលបានបោះ។ ការអនុម័តវិសោធនកម្មណាមួយចំពោះមាត្រា ១១ ទាមទារសំលេង៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ។

(៣)

(ក) វិសោធនកម្មមាត្រាទាំងឡាយដូចមានចែងក្នុងកថាខណ្ឌទី(១) ត្រូវចូលជាធរមាន ១(មួយ)ខែ បន្ទាប់ពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីការយល់ព្រមដែលធ្វើឡើងស្របតាមដំណើរការរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗដោយអគ្គនាយក ពីប្រទេសហត្ថលេខីចំនួន៣/៤(បីភាគបួន)ដែលជាសមាជិកនៃសន្និបាត នាពេលសន្និបាតបានអនុម័តវិសោធនកម្មនេះ។

(ខ) ការទទួលយកវិសោធនកម្មណាមួយចំពោះមាត្រាទាំងនេះ ត្រូវចងភ្ជាប់រដ្ឋហត្ថលេខីទាំងអស់ ដែលជារដ្ឋហត្ថលេខីនៅពេលដែលវិសោធនកម្មទាំងនេះអនុម័តដោយសន្និបាត។ ចំពោះវិសោធនកម្មណាមួយបង្កើតកាតព្វកិច្ចហិរញ្ញវត្ថុចំពោះរដ្ឋហត្ថលេខីនេះ ឬបង្កើនកាតព្វិកិច្ចនេះ ត្រូវចងភ្ជាប់តែរដ្ឋហត្ថលេខីដែលបានជូនដំណឹងពីការយល់ព្រមលើវិសោធនកម្មទាំងនេះតែប៉ុណ្ណោះ។

(គ) វិសោធនកម្មណាមួយដែលត្រូវបានទទួលយកហើយបានចូលជាធរមានស្របតាមអនុកថាខណ្ឌ(ក) ត្រូវចងភ្ជាប់រដ្ឋទាំងអស់ ដែលក្លាយជារដ្ឋហត្ថលេខីបន្ទាប់ពីកាលបរិច្ឆេទដែលវិសោធនកម្មត្រូវបានអនុម័តដោយសន្និបាត។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ
### មាត្រា១៥
### ការក្លាយជាភាគីនៃសន្ធិសញ្ញា

(១) រដ្ឋជាសមាជិកណាមួយនៃសហភាពអន្តរជាតិ(ប៉ារីស)ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះដោយៈ

(i) ចុះហត្ថលេខា បន្ទាប់ពីតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬ

(ii) តម្កល់លិខិតុបករណ៍នៃការចូលជាសមាជិក។

(២) លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ត្រូវតម្កល់ជូនអគ្គនាយក។

## មាត្រា១៦

## ការចូលជាធរមាននៃសន្ធិសញ្ញា

(១) សន្ធិសញ្ញានេះត្រូវចូលជាធរមានចំពោះរដ្ឋប្រាំ(៥)ដំបូង ដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន រយៈពេលបី(៣)ខែបន្ទាប់ពីកាលបរិច្ឆេទ ដែលលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទីប្រាំត្រូវបានតម្កល់។

(២) សន្ធិសញ្ញានេះត្រូវចូលជាធរមានចំពោះរដ្ឋផ្សេងទៀត រយៈពេលបី(៣)ខែបន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនេះបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន ប្រសិនបើគ្មានការបង្ហាញកាលបរិច្ឆេទក្រោយនៅក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក។ ក្នុងករណីក្រោយនេះ សន្ធិសញ្ញានេះត្រូវចូលជាធរមានចំពោះប្រទេសនេះតាមកាលបរិច្ឆេទដែលបានបង្ហាញនេះ។

## មាត្រា១៧

## ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា

(១) រដ្ឋហត្ថលេខីណាមួយ អាចប្រកាសដកខ្លួនចេញពីសន្ធិសញ្ញានេះ ដោយការជូនដំណឹងទៅអគ្គនាយក។

(២) ការប្រកាសដកខ្លួនចេញ ត្រូវមានអានុភាពរយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីថ្ងៃដែលអគ្គនាយកទទួលបានការជូនដំណឹងនេះ។

(៣) សិទ្ធិប្រកាសដកខ្លួនចេញ ដូចមានចែងក្នុងកថាខណ្ឌ(១) មិនត្រូវអនុវត្តដោយរដ្ឋហត្ថលេខីណាមួយមុនពេលផុតកំណត់រយៈពេល៥(ប្រាំ)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទដែលរដ្ឋហត្ថលេខីនេះក្លាយជាភាគីសន្ធិសញ្ញានេះ។

(៤) ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញានេះដោយរដ្ឋហត្ថលេខីមួយដែលបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងមាត្រា៧(១)(ក) ទាក់ទងនឹងស្ថាប័នតម្កល់ដែលទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ត្រូវបញ្ចប់ឋានៈនេះ ១(មួយ)ឆ្នាំ បន្ទាប់ពីថ្ងៃដែលអគ្គនាយកទទួលបានការជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌទី(១)។

## មាត្រា១៨

## ការចុះហត្ថលេខា និងភាសានៃសន្ធិសញ្ញា

(១)

(ក) សន្ធិសញ្ញានេះត្រូវចុះហត្ថលេខាក្នុងឯកសារដើមមួយ ជាភាសាអង់គ្លេស និងជាភាសាបារាំង ដែលអត្ថបទទាំងពីរមានយថាភាពដូចគ្នា។

(ខ) អត្ថបទផ្លូវការនៃសន្ធិសញ្ញានេះត្រូវបង្កើតឡើងដោយអគ្គនាយក បន្ទាប់ពីប្រឹក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ ហើយក្នុងរយៈពេល២(ពីរ)ខែរាប់ចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខា ត្រូវបង្កើតជាភាសាផ្សេងទៀតតាមរយៈការចុះហត្ថលេខាលើអនុសញ្ញាស្តីពីការបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(គ) អត្ថបទផ្លូវការនៃសន្ធិសញ្ញានេះត្រូវបង្កើតឡើងដោយអគ្គនាយក បន្ទាប់ពីប្រឹក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ ជាភាសាអារ៉ាប់ ជាភាសាអាឡឺម៉ង់ ជាភាសាអ៊ីតាលី ជាភាសាជប៉ុន និងជាភាសាព័រទុយហ្គាល់ និងភាសាផ្សេងទៀត ដូចដែលសន្និបាតកំណត់។

(២) សន្ធិសញ្ញានេះនៅតែចំហសម្រាប់ការចុះហត្ថលេខានៅទីក្រុង ប៊ុយដាប៉ែស រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៧៧។

## មាត្រា១៩

## ការតម្កល់សន្ធិសញ្ញា ការបញ្ជូនច្បាប់ចម្លង ការចុះបញ្ជីសន្ធិសញ្ញា

(១) អត្ថបទដើមនៃសន្ធិសញ្ញានេះ នៅពេលឈប់បើកចំហសម្រាប់ចុះហត្ថលេខា ត្រូវតម្កល់ជូនអគ្គនាយក។

(២) អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លងពីរច្បាប់នៃសន្ធិសញ្ញានិងបទបញ្ជា ដែលបានបញ្ជាក់ថាត្រឹមត្រូវដោយអគ្គនាយក ទៅរដ្ឋាភិបាលនៃរដ្ឋទាំងអស់ដូចមានចែងក្នុងមាត្រា១៥(១) ទៅអង្គការអន្តររដ្ឋាភិបាល ដែលអាចដាក់សេចក្តីប្រកាសតាមមាត្រា៩(១)(ក)និងទៅរដ្ឋាភិបាលនៃរដ្ឋផ្សេងទៀតតាមការស្នើសុំ។

(៣) អគ្គនាយកត្រូវចុះបញ្ជីសន្ធិសញ្ញានេះនៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

(៤) អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លងពីរច្បាប់នៃវិសោធនកម្មណាមួយនៃសន្ធិសញ្ញានេះនិងបទបញ្ជា ដែលបានបញ្ជាក់ថាត្រឹមត្រូវដោយអគ្គនាយក ទៅរដ្ឋហត្ថលេខីទាំងអស់ ទៅអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលទាំងអស់ និង តាមការស្នើសុំ ទៅរដ្ឋាភិបាលនៃរដ្ឋផ្សេងទៀត និងទៅអង្គការអន្តររដ្ឋាភិបាលផ្សេងទៀតដែលអាចដាក់សេចក្តីប្រកាសតាមមាត្រា៩(១)(ក)។

## មាត្រា២០

## ការជូនដំណឹង

អគ្គនាយកត្រូវជូនដំណឹងទៅរដ្ឋហត្ថលេខី អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលនិងរដ្ឋដែលមិនមែនជាសមាជិកសហភាព តែជាសមាជិកសហភាពអន្តរជាតិ(ប៉ារីស) ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម នូវៈ

(i) ការចុះហត្ថលេខាតាមមាត្រា១៨

(ii) ការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកតាមមាត្រា១៥(២)

(iii) សេចក្តីប្រកាសដែលបានដាក់តាមមាត្រា៩(១)(ក) និងការជូនដំណឹងពីការដកចេញតាមមាត្រា៩(២)ឬ(៣)

(iv) កាលបរិច្ឆេទចូលជាធរមាននៃសន្ធិសញ្ញានេះតាមមាត្រា១៦(១)

(v) សេចក្តីជូនដំណឹងតាមមាត្រា៧និងមាត្រា៨ និងសេចក្តីសម្រេចតាមមាត្រា៨

(vi) ការទទួលយកវិសោធនកម្មនៃសន្ធិសញ្ញានេះតាមមាត្រា១៤(៣)

(vii) វិសោធនកម្មណាមួយនៃបទបញ្ជា

(viii) កាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មសន្ធិសញ្ញានេះនិងបទបញ្ជា

(ix) ការប្រកាសដកខ្លួនចេញដែលទទួលបានតាមមាត្រា១៧។